# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦៥ សសរ

## សេចក្តីសម្រេច

## ស្តីពីការចាត់តាំងគណៈកម្មការរៀបចំព្រះរាជពិធីអភិសេក

## ថ្វាយព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី

### រាជរដ្ឋាភិបាលកម្ពុជា

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០០៤/០៣ ចុះថ្ងៃទី ១១ ខែតុលាឆ្នាំ ២០០៤ ប្រកាស អោយច្បាប់ ស្តីពីការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ
- បានឃើញសេចក្តីសម្រេច លេខ ករស/សសរ/១០០៤/០០១ របស់ក្រុមប្រឹក្សារាជសម្បត្តិ ស្តីពីការជ្រើសរើសសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ជាព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការងារចាំបាច់

### ស ម្រេ ច

**ប្រការ ១.-** បង្កើតគណៈកម្មការមួយទទួលបន្ទុករៀបចំព្រះរាជពិធីអភិសេក ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ដូចមានសមាសភាពខាងក្រោមនេះ :

| | | |
|---|---|---|
| ១- សម្តេច ចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ គង់ សំអុល ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីព្រះបរមរាជវាំង និងជាប្រធានគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ | | ប្រធាន |
| ២- ឯកឧត្តម មិន ឃិន | អនុប្រធានអចិន្ត្រៃយ៍ គ.ប.ជ.អ និងជារដ្ឋលេខាធិការ ក្រសួងធម្មការ និង សាសនា | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- ឯកឧត្តម ហ៊ីម ឆែម | រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ៤- អ្នកឧកញ៉ា ព្រះស្តេចធិបតី ខិន ព្រហ្ម | ផ្នែកធម្មការព្រះបរមរាជវាំង | សមាជិក |
| ៥- ឧកញ៉ា សុធម្មប្រីជា នូ ចាន់ | ផ្នែកធម្មការព្រះបរមរាជវាំង | សមាជិក |
| ៦- អ្នកឧកញ៉ា ភក្តីព្រះស្តេច ហេង គីមគុណ | ផ្នែកធម្មការព្រះបរមរាជវាំង | សមាជិក |

| | | |
|---|---|---|
| ៧- ព្រះជយាធិបតី គង់ គេន | ប្រធានផ្នែកបារគូ | សមាជិក |
| ៨- ឯកឧត្តម អ៊ុក រ៉ាប៊ុន | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩- ឯកឧត្តម ខាច់ ផែន | រដ្ឋលេខាធិការក្រសួងពត៌មាន | សមាជិក |
| ១០- ឯកឧត្តម ឡុង វិសាលោ | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១១- ឯកឧត្តម ហុក ឡុងឌី | អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ១២- ឯកឧត្តម សៅ សុខា | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៣- ឯកឧត្តម យូ ស៊ុនឡុង | អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ១៤- ឯកឧត្តម កែប ជុតិមា | អភិបាលរាជធានីភ្នំពេញ | សមាជិក |
| ១៥- ឯកឧត្តម គុយ សុផល | រដ្ឋលេខាធិការព្រះបរមរាជវាំង | សមាជិក |
| ១៦- ឯកឧត្តម ជុំ ទៀន | រដ្ឋលេខាធិការព្រះបរមរាជវាំង | សមាជិក |
| ១៧- ឯកឧត្តម ជា សុខុម | អគ្គលេខាធិការរងទី១ គ.ប.ជ.អ | សមាជិក |
| ១៨- ឯកឧត្តម ឈា ហាន | អនុរដ្ឋលេខាធិការព្រះបរមរាជវាំង | សមាជិក |
| ១៩- ឯកឧត្តម ជា តាន | អគ្គលេខាធិការរង នៃ គ.ប.ជ.អ | សមាជិក |
| ២០- ឯកឧត្តម ញៀម ចាំលី | អគ្គលេខាធិការរង នៃ គ.ប.ជ.អ | សមាជិក |
| ២១- ឯកឧត្តម សូ ស៊ីខួន | អនុរដ្ឋលេខាធិការព្រះបរមរាជវាំង | សមាជិក |
| ២២- ឯកឧត្តម ប៊ូន លីមហេង | ទីប្រឹក្សាទីស្តីអមការគណៈរដ្ឋមន្ត្រី | សមាជិក |
| ២៣- ឯកឧត្តម រស់ គង់ | អគ្គលេខាធិការរង នៃ គ.ប.ជ.អ | សមាជិក |
| ២៤- ឯកឧត្តម តន់ យ៉ាន | អគ្គនាយកវិទ្យុជាតិកម្ពុជា | សមាជិក |
| ២៥- ឯកឧត្តម ឈិន កេតនា | អគ្គលេខាធិការរង នៃ គ.ប.ជ.អ | សមាជិក |
| ២៦- ឯកឧត្តម គីម គុណាវឌ្ឍន៍ | អគ្គនាយកទូរទស្សន៍ជាតិកម្ពុជា | សមាជិក |
| ២៧- ឯកឧត្តម សួន ឈាងលី | ប្រធាននាយកដ្ឋានអង្គរក្ស | សមាជិក |
| ២៨- ឯកឧត្តម សេង សុខ | មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ | សមាជិក |
| ២៩- ឯកឧត្តម ហេង ពៅ | ស្នងការនគរបាលរាជធានីភ្នំពេញ | សមាជិក |
| ៣០- លោក អ៊ាត សីលា | ប្រធាននាយកដ្ឋានពិធីការ គ.ប.ទ | សមាជិក |

ប្រការ ២ .- គណៈកម្មការនេះមានភារកិច្ច :

- ទទួលបន្ទុករៀបចំព្រះរាជពិធីអភិសេក ព្រះមហាក្សត្រថ្មី ឱ្យបានប្រព្រឹត្តទៅស្របតាមព្រះរាជប្រពៃណី ជាតិប្រពៃណីព្រះពុទ្ធសាសនា.
- សិក្សាស្រាវជ្រាវឯកសារពាក់ព័ន្ធ រូបភាពចាត់តាំង ស្តីពីព្រះរាជពិធីអភិសេក.
- លើកគម្រោងរូបភាពចាត់តាំង ព្រះរាជពិធីអភិសេកឱ្យបានសក្តិសម.
- សាងសង់មហាបុស្បុកដ៏ល្អមួយ បំពាក់ក្បូរក្បាច់រចនាតាមរចនាបទខ្មែរ សម្រាប់ស្រង់ព្រះសុគន្ធវារី.

- យាង-អញ្ជើញ ព្រះរាជវង្សានុវង្ស ឧត្តមប្រឹក្សាព្រះមហាក្សត្រ ថ្នាក់ដឹកនាំព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ឯកអគ្គរាជទូត-រដ្ឋទូត-ភារធារី ចូលរួម តាមចំនួនកំណត់.
- ធ្វើការផ្សព្វផ្សាយទូលាយតាមបណ្តាញឃោសនាជាតិ-អន្តរជាតិ អំពីព្រះរាជជីវប្រវត្តិព្រះមហាក្សត្រថ្មី និងឯកសារផ្សេងៗ តាមសំណូមពរចាំបាច់.
- រៀបចំព្រះរាជកកុធភ័ណ្ឌ មានព្រះភូសាជាយ-មកុដ-សុពណ៌បាទ-ព្រះរាជបល្ល័ង្ក-ព្រះសល្ទេង-បុស្បុកទៀនជ័យ គ្រឿងហែរក្សនគ្រប់មុខ ។
- ធ្វើព្រះរាជកម្មវិធីលំអិត សម្រាប់ដំណើរការងារក្នុងព្រះរាជពិធីអភិសេក.
- រក្សាការពារសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់ ឱ្យបានល្អប្រសើរគ្រប់ទីកន្លែង.

ប្រការ ៣.- ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវត្រៀមលក្ខណៈដោះស្រាយ សម្ភារៈ ថវិកា បំរើការរៀបចំព្រះរាជពិធីរាជាភិសេក ឱ្យបានល្អប្រសើរ និងទាន់ពេលវេលា ។

ប្រការ ៤.- គណៈកម្មការនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការជំនាញមួយចំនួន ជាជំនួយការ តាមតម្រូវការចាំបាច់.

ប្រការ ៥.- គណៈកម្មការនេះ មានទីតាំងអចិន្ត្រៃយ៍ នៅអគ្គលេខាធិការដ្ឋានគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ និងប្រើប្រាស់ត្រារបស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ។

ប្រការ ៦.- ឯកឧត្តម ដូចមាននាមប្រការមួយ ត្រូវទទួលភារកិច្ចអនុវត្តតាមស្មារតី សេចក្តីសំរេចនេះ ឱ្យសម្រេចលទ្ធផលល្អប្រសើរ ។

ប្រការ ៧.- សេចក្តីសំរេចនេះ មានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាប "
- ដូចក្នុងប្រការមួយ
  " ដើម្បីសហការអនុវត្តន៍ "
- ឯកសារ